# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សហគ្រាស **អេ.ប៊ី.ស៊ី**

A.B.C

## សូមគោរពជូន
## លោកជំទាវរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**កម្មវត្ថុ៖** សំណើសុំផ្ទេរសិទ្ធិគ្រប់គ្រង និងកាន់កាប់សហគ្រាស **អេ.ប៊ី.ស៊ី** A.B.C

**យោង ៖** -វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ ០០០០០១២៣ ចុះថ្ងៃទី ខែ ឆ្នាំ ២០

-លិខិតផ្ទេរសិទ្ធិក្នុងការកាន់កាប់ និងគ្រប់គ្រងអាជីវកម្មសហគ្រាស ចុះថ្ងៃទី ខែ ឆ្នាំ ២០

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំមានកិត្តិយសសូមជម្រាបជូន លោកជំទាវរដ្ឋមន្ត្រី មេត្តាជ្រាបថា៖ យើងខ្ញុំបានសម្រេចចិត្តធ្វើការផ្ទេរសិទ្ធិគ្រប់គ្រង និងកាន់កាប់សហគ្រាស **អេ.ប៊ី.ស៊ី** A.B.C ដែលមានទីស្នាក់ការលេខ១២៣ ផ្លូវលេខ១២៣ សង្កាត់១២៣ ខណ្ឌ១២៣ រាជធានីភ្នំពេញ ពី លោក **ក** មកលោក **ខ** ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោកជំទាវរដ្ឋមន្ត្រី មេត្តាអនុញ្ញាតទទួលចុះបញ្ជីលើការផ្ទេរសិទ្ធិគ្រប់គ្រង និងកាន់កាប់សហគ្រាសយើងខ្ញុំដោយក្តីអនុគ្រោះ ។

សូម លោកជំទាវរដ្ឋមន្ត្រី ទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

ថ្ងៃទី ខែ ឆ្នាំ ២០

**ឯកកម្មសិទ្ធិករ**

(ហត្ថលេខា និងត្រា)

**ក**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## លិខិតផ្ទេរសិទ្ធិក្នុងការកាន់កាប់ និងគ្រប់គ្រងអាជីវកម្មសហគ្រាស

ខ្ញុំបាទឈ្មោះ **ក** ជាឯកកម្មសិទ្ធិករសហគ្រាស **អេ.ប៊ី.ស៊ី** A.B.C ដែលមានអត្តលេខចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ ០០០០០១២៣ ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០ ខ្ញុំបាទបានផ្ទេរសិទ្ធិកាន់កាប់ និងគ្រប់គ្រងអាជីវកម្មសហគ្រាស **អេ.ប៊ី.ស៊ី** A.B.C ផ្ទេរជូនទៅលោក **ខ** សញ្ជាតិ ខ្មែរ ជាឯកកម្មសិទ្ធិករថ្មី ដែលមានទីស្នាក់ការលេខ១២៣ ផ្លូវលេខ១២៣ សង្កាត់១២៣ ខណ្ឌ១២៣ រាជធានីភ្នំពេញ ពី លោក **ក** មកលោក **ខ** ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាល់ការទទួលខុសត្រូវផ្សេងៗ និងការដឹកនាំអាជីវកម្មរបស់សហគ្រាស **អេ.ប៊ី.ស៊ី** A.B.C គឺលោក **ខ** ជាអ្នកទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ទៅថ្ងៃអនាគត ។

ថ្ងៃទី ខែ ឆ្នាំ ២០

| | |
|---|---|
| **អ្នកផ្ទេរសិទ្ធិ** | **អ្នកទទួលសិទ្ធិ** |
| (ហត្ថលេខា និងស្នាមមេដៃ) | (ហត្ថលេខា និងស្នាមមេដៃ) |
| **ក** | **ខ** |